# ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ ជួបឯកឧត្តមឯកអគ្គរដ្ឋទូតបារាំងប្រចាំកម្ពុជា



នៅព្រឹកថ្ងៃ ២៥ ខែ កក្កដា ឆ្នាំ២០១៤ ឯកឧត្តម ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានទទួលជួប ឯកឧត្តម **Jean-Claude POIMBOEUF** ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋបារាំង ប្រចាំកម្ពុជា និង សហការី ដើម្បីពិភាក្សាការងារ នៅទីស្តីការក្រសួង ។



ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានសម្តែងស្វាគមន៍ និងវាយតម្លៃខ្ពស់ចំពោះទំនាក់ទំនងដ៏ល្អលើវិស័យការទូត និងសេដ្ឋកិច្ច រវាងកម្ពុជា–បារាំង ដែលមានជាយូរលង់មកហើយ ។ ឯកឧត្តម ទេសរដ្ឋមន្ត្រី បានថ្លែងអំណរគុណចំពោះរដ្ឋាភិបាលបារាំង ដែលបានរួមចំណែកយ៉ាងសំខាន់ ក្នុងការស្វែងរកសុខសន្តិភាព និងសកម្មភាពអភិវឌ្ឍន៍នៅកម្ពុជា ។ ក្នុងនោះជំនួយទាក់ទងលើវិស័យទឹកស្អាត រដ្ឋាភិបាលបារាំង តាមរយៈទីភ្នាក់ងារអភិវឌ្ឍន៍បារាំង AFD បានសហការឧបត្ថម្ភ

ជាជំនួយ និងហិរញ្ញប្បទានជាច្រើនដល់រដ្ឋាករទឹកស្វយ័តទីក្រុងភ្នំពេញ តាំងពីទសវត្សរ៍ ឆ្នាំ៩0 មកម្លេះ ហើយ បើយើងរំលឹកពីទំនាក់ទំនងក្នុងអតីតកាល ប្រទេសបារាំងបានជួយកសាងរោងចក្រផលិតទឹកស្អាតនៅស្ថានីយ៍ជ្រោយចង្វារ តាំងពីឆ្នាំ១៨៩៥ មកម្លេះ និងបន្ទាប់មក បានកសាងស្ថានីយ៍ចំនួនពីរទៀត គឺស្ថានីយ៍ចំការមន នៅឆ្នាំ១៩៥៨ និង ស្ថានីយ៍ភូមិព្រែក នៅឆ្នាំ១៩៦៦ ដែលបច្ចុប្បន្នជាទីតាំងរដ្ឋាករទឹកស្វយ័តទីក្រុងភ្នំពេញ។ ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានបញ្ជាក់ថា: នៅក្នុងអណត្តិទី៥ នេះ អតីតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ត្រូវបានបំបែកជាពីរក្រសួង គឺ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងក្រសួង រ៉ែ និង ថាមពល ។ បច្ចុប្បន្ន ក្រសួងឧស្សាហកម្ម និងសិប្បកម្ម មាននាយកដ្ឋាន និង វិទ្យាស្ថានមួយចំនួនដែលត្រូវការនូវជំនួយបច្ចេកទេស ដូចជាៈវិទ្យាស្ថានស្តង់ដាជាតិ កំពុងមានតម្រូវការផ្នែកការបំពាក់ឧបករណ៍ ដើម្បីពិសោធន៍ និងធ្វើតេស្ត ពីកំរិតស្តង់ដា លើផលិតផលទំនិញ និងសម្ភារៈប្រើប្រាស់ដ៏ទៃទៀត រីឯមជ្ឈមណ្ឌលមាត្រាសាស្ត្រកម្ពុជា ក៏នៅមានការខ្វះខាតផ្នែកបំពាក់ឧបករណ៍វាស់វង្វាល់បែបទំនើប និងការបណ្តុះបណ្តាលធនធានមនុស្ស ។ ជាមួយគ្នានេះ ឯកឧត្តម ក៏បានលើកឡើងពីតម្រូវការជំនួយបច្ចេកទេស ដើម្បីពង្រឹងអគ្គនាយកដ្ឋានសហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម ដែលទទួលភារកិច្ច ក្នុងការចុះបញ្ជីសហគ្រាសធុនតូច និងមធ្យមនៅកម្ពុជា ដែលមានជាង៥សែនមូលដ្ឋាន ។ កិច្ចការនេះក្រសួងកំពុងរៀបចំដាក់ឱ្យដំណើរការការចុះបញ្ជីតាមប្រព័ន្ធ **Intranet** (ប្រព័ន្ធទំនាក់ទំនងអ៊ិនធឺណេតផ្ទៃក្នុង) ដើម្បីដំណើរការឯកសារមានភាពរហ័ស ចំណេញពេលវេលា និងចំណាយតិច ។

ដោយការងារទឹកស្អាត ជាការងារអាទិភាពដែលរាជរដ្ឋាភិបាលកម្ពុជាបានយកចិត្តទុកដាក់បំផុត ដើម្បីសម្រេចបានតាមគោលដៅអភិវឌ្ឍន៍សហវត្សន៍ ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានលើកឡើងពីការខិតខំរបស់ក្រសួង និងការប្តេជ្ញាចិត្តរបស់ឯកឧត្តមផ្ទាល់ ធ្វើយ៉ាងណាឱ្យវិស័យទឹកស្អាតនេះ ពង្រីកបានវិសាលភាព ក្នុងការផ្គត់ផ្គង់ឱ្យដល់ទីប្រជុំជន និងធានាបាននូវគោលការណ៍យ៉ាងតិច ០៣យ៉ាង គឺគុណភាព–សុវត្ថិភាព និងចិរភាព ដោយលើកទឹកចិត្តឱ្យវិស័យឯកជនចូលរួមវិនិយោគ ដែលអាចទទួលអជ្ញាប័ណ្ណរហូតដល់រយៈពេល២0 ឆ្នាំ។ ទោះជាយ៉ាងណា កិច្ចការនេះ ពិតជាត្រូវការចាំបាច់នូវជំនួយឧបត្ថម្ភ និងកិច្ចសហការពីដៃគូ ដែលឯកឧត្តម ក៏បានស្នើឱ្យភាគីបារាំងពិនិត្យលទ្ធភាពជួយបន្ថែមលើវិស័យអភិវឌ្ឍន៍ទឹកស្អាតនៅកម្ពុជា ។

ឯកឧត្តម **Jean-Claude POIMBOEUF** ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋបារាំង ប្រចាំកម្ពុជា បានសម្តែងទឹកចិត្តរីករាយចំពោះការបំពេញបេសកកម្មការទូតនៅកម្ពុជា និងវាយតម្លៃខ្ពស់ចំពោះភាពរីកចម្រើនលើគ្រប់វិស័យរបស់កម្ពុជា ។

ក្នុងនោះវិស័យរោងចក្រវាយនភ័ណ្ឌមានការរីកចម្រើនប្រកបដោយសក្តានុពល ។ ឯកឧត្តម បានបញ្ជាក់ថា: ពេលកន្លងទៅថ្មីៗនេះ គណៈប្រតិភូតំណាងរោងចក្រវាយនភ័ណ្ឌមកពីប្រទេសបារាំងបានមកបំពេញទស្សនៈកិច្ចនៅកម្ពុជា ដើម្បីស្វែងយល់ពីសក្តានុពល និងលក្ខខ័ណ្ឌការងារ ហើយបានត្រៀមនឹងបើកការិយាល័យទំនាក់ទំនង ជម្រុញការនាំចេញ និងការងារទទួលខុសត្រូវសង្គម ក្នុងកំឡុងខែតុលា ខាងមុខនេះ នៅរាជធានីភ្នំពេញ ។ ទាក់ទង និងជំនួយអភិវឌ្ឍន៍ទឹកស្អាត ឯកឧត្តម បានបញ្ជាក់ថាៈនៅសប្តាហ៍ក្រោយ ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង AFD និងចុះហត្ថលេខាផ្តល់ហិរញ្ញប្បទានដល់រដ្ឋាករទឹកស្វយ័តខេត្តសៀមរាប សម្រាប់ជួយលើប្រព័ន្ធគ្រប់គ្រងប្រភពទឹកស្អាត ។

ជាទីបញ្ចប់ ឯកឧត្តម ឯកអគ្គរដ្ឋទូតបារាំង ប្រចាំកម្ពុជា បានវាយតម្លៃខ្ពស់ ចំពោះការវិវឌ្ឍន៍ដ៏ល្អនៃសភាពការណ៍នយោបាយនៅកម្ពុជា ។ ឯកឧត្តម សង្ឃឹមថា កម្ពុជា នឹងរួមគ្នាអភិវឌ្ឍន៍ប្រទេសជាតិមានការីកចម្រើនជាលំដាប់ ។ ជាមួយគ្នានេះ ឯកឧត្តម នឹងខិតខំសហការដ៏ល្អ ក្នុងសកម្មភាពអភិវឌ្ឍន៍នៅកម្ពុជា ។ ក្នុងនោះ ឯកឧត្តមនឹងខិតខំជួយទាក់ទាញអ្នកវិនិយោគ បារាំងមកកម្ពុជាឱ្យកាន់តែច្រើនឡើងថែមទៀត ។